**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៤០...ស.ស.រ

## សេចក្តីសម្រេច

## ស្តីពីការបង្កើតគណៈកម្មការរៀបចំប្រក្រតីភាពដីធ្លី នៅក្នុងអាងទឹកតាមោក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញសេចក្តីសម្រេចលេខ ៣៨ សសរ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការបង្កើតប្រតិភូចុះពិនិត្យជាក់ស្តែងលើសកម្មភាពចាក់ដីលុបអាងទឹកតាមោក និងសកម្មភាពអសកម្មនានា ដែលមាននៅក្នុងអាងទឹកតាមោក
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**ប្រការ ១:** ត្រូវបានបង្កើតគណៈកម្មការរៀបចំប្រក្រតីភាពដីធ្លី នៅក្នុងអាងទឹកតាមោក រួមមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ប្រធាន

២- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៣- ឯកឧត្តម **ឈុន សិរុន** អភិបាលខេត្តកណ្តាល សមាជិក

www.pheakdeylaw.com

៤- ឯកឧត្តម **ម៉ុន ម៉ារ៉ន** អគ្គនាយកបច្ចេកទេសក្រសួងធនធានទឹក និងឧតុនិយម សមាជិក

៥- លោក **ខឹង សេងអ៊ឹម** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រសួងធនធានទឹក និងឧតុនិយម សមាជិក

**ប្រការ ២:** គណៈកម្មការរៀបចំប្រក្រតីភាពដីធ្លី នៅក្នុងអាងទឹកតាមោក មានភារកិច្ចដូចតទៅ :

- កំណត់ទីតាំងដីធ្លី ដែលត្រូវទុកជាតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល និងបរិមាណសាច់ដី ដែលត្រូវយកចេញ
- ចាត់ចែងដីធ្លី ដើម្បីរៀបចំឱ្យមានប្រក្រតីភាពឡើងវិញ ទៅតាមផែនការកំណត់
- សាច់ដីដែលយកចេញ ឬ លក់ សុទ្ធសឹងជាផែនការ និងជាចំណូលរបស់រដ្ឋ ។

**ប្រការ ៣:** - ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធាននៃគណៈកម្មការនេះ មានភារកិច្ចទទួលខុសត្រូវរួម លើភារកិច្ចដូចមានចែងក្នុងប្រការ ២ នៃសេចក្តីសម្រេចនេះ ។

- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធាននៃគណៈកម្មការនេះ មានភារកិច្ចទទួលខុសត្រូវលើការរៀបចំចាត់ចែងសាច់ដីខាងលើ ។

**ប្រការ ៤:** គណៈកម្មការរៀបចំប្រក្រតីភាពដីធ្លីនៅក្នុងអាងទឹកតាមោក ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ ៥:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជនដូចមានឈ្មោះចែងក្នុងប្រការ ១ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com